ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៤ អយក.សណន

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៧

# សេចក្តីណែនាំ
## ស្តីពី
## ការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា

យោង៖
- ប្រកាសលេខ២២៤៦៧ អយក.ប្រក. ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយឯកសារកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាក់ទី៤ ទី៥ និងទី៦
- ប្រកាសលេខ ៣០៩៣អយក.ប្រក. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤
- ប្រកាសលេខ ២៦៤២អយក.ប្រក. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៥
- ប្រកាសលេខ ១២២៣អយក.ប្រក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៦
- លិខិតលេខ ២៥អយក.សណន ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណេះទូទៅពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ដើម្បីផ្តល់ឱកាសឱ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេសសម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។

ដើម្បីអនុវត្តកម្មវិធីសិក្សានិងសៀវភៅសិក្សាគោលភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ៖

### ១. ការប្រើប្រាស់សៀវភៅភាសាអង់គ្លេស

គ្រប់គ្រឹះស្ថានសិក្សាបឋមសិក្សាចំណេះទូទៅសាធារណៈទាំងអស់ ត្រូវប្រើប្រាស់សៀវភៅភាសាអង់គ្លេស "English Grade 4, Grade 5 and Grade 6" ជាសៀវភៅសិក្សាគោលតែមួយគត់ក្នុងការបង្រៀននិងរៀននៅតាមសាលាបឋមសិក្សាទូទាំងប្រទេស។

### ២. ការប្រើប្រាស់ម៉ោងសិក្សា

២.១. ការបង្រៀននិងរៀនភាសាអង់គ្លេសនេះ ត្រូវបែងចែករបាយម៉ោងឱ្យបានច្បាស់លាស់ក្នុងកាលវិភាគប្រចាំសប្តាហ៍ ដោយអនុវត្ត០២ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ហើយ០១ម៉ោងសិក្សាមានរយៈពេល៤០នាទី

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ / ២១៧ ២៥៣ / ៤២៦ ៥៤១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

២.២. ប្រធានកម្រងត្រូវសហការជាមួយនាយកសាលារៀនដើម្បីកំណត់ម៉ោងក្នុងកាលវិភាគច្បាស់លាស់ឱ្យគ្រប់សាលាបឋមសិក្សាអនុវត្តការបង្រៀននិងរៀនភាសាអង់គ្លេសបានឯកភាពគ្នា។

## ៣. ការប្រើប្រាស់ធនធានគ្រូបង្រៀន

៣.១. នាយកសាលារៀនចាត់តាំងគ្រូបង្រៀនដែលមានចំណេះដឹងផ្នែកភាសាអង់គ្លេស ឬធ្លាប់បានចូលរួមក្នុងវគ្គតម្រង់ទិសការប្រើប្រាស់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ជាគ្រូបង្គោលសម្រាប់បង្រៀនទាំងបីកម្រិតថ្នាក់។ ចំពោះម៉ោងដែលគ្រូបង្រៀននោះនៅសេសសល់ ត្រូវជួយការងាររដ្ឋបាល ឬបណ្ណាល័យសាលារៀន

៣.២. ចំពោះសាលារៀនដែលគ្រូពុំទាន់បានទទួលការបណ្តុះបណ្តាលការណែនាំប្រើប្រាស់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ទេ គណៈគ្រប់គ្រងសាលារៀន ត្រូវជ្រើសរើសយកគ្រូបង្រៀនដែលចេះភាសាអង់គ្លេសសម្រាប់បង្រៀនមុខវិជ្ជាភាសាអង់គ្លេសពីថ្នាក់ទី៤ដល់ទី៦ ហើយសមាសភាពគ្រូទាំងនោះ ជាមុខសញ្ញាក្នុងការទទួលការបណ្តុះបណ្តាលជំនាញ ឬប៉ប៉នសមត្ថភាពផ្នែកកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅពេលអនាគត។

## ៤. ការកំណត់ពិន្ទុ

ការដាក់ពិន្ទុ ត្រូវធ្វើការវាយតម្លៃទៅលើសមាសភាគទាំងបួននៃភាសាអង់គ្លេស គឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ដែលពិន្ទុសរុបស្មើនឹង ១០ពិន្ទុ ដូចមុខវិជ្ជាដទៃទៀតដែរ។

ទទួលសេចក្តីណែនាំនេះ គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត គ្រឹះស្ថានអប់រំ ត្រូវចាត់ចែងអនុវត្តជាក់ហ៊ិត និងត្រូវធ្វើការផ្សព្វផ្សាយបន្តតាមអង្គភាពក្រោមឱវាទ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**